**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.....០៤២.....ន. គ. ស/[illegible]

# សារាចរណែនាំ

# ស្តីពី

# លក្ខខណ្ឌ បែបបទ និងនីតិវិធី ក្នុងការទទួលបានសិទ្ធិបន្តចុះហត្ថលេខា លើរបាយការណ៍គណនេយ្យ ឬ/និង របាយការណ៍សវនកម្ម សម្រាប់គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស

ដោយមានភាពចាំបាច់នៃតម្រូវការសេវាគណនេយ្យនិងសវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមបទប្បញ្ញត្តិដែលបានដាក់ឱ្យអនុវត្តជាធរមាន និងអនុលោមតាមប្រកាសលេខ ១០៣ សហវ. ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណនេយ្យករជំនាញ និងសវនករប្រតិស្រុតជាជនបរទេស មានសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍សវនកម្ម **និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស.**) សម្រេចបន្តសិទ្ធិចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍សវនកម្មជូនគណនេយ្យករជំនាញ និងសវនករប្រតិស្រុតជាជនបរទេស សម្រាប់រយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ និងសូមធ្វើការណែនាំដូចខាងក្រោម÷

## ក- លក្ខខណ្ឌនៃការស្នើសុំចុះបញ្ជី

គណនេយ្យករជំនាញ ឬ/និងសវនករប្រតិស្រុតជាជនបរទេស ដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកនៃ **ន.គ.ស.** ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

### ក.១. លក្ខខណ្ឌសម្រាប់ការស្នើសុំចុះបញ្ជីលើកដំបូង (សិទ្ធិចុះហត្ថលេខា)

- ត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងតិចរយៈពេល៦០(ហុកសិប) ថ្ងៃ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជី និងត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី១៨២ (មួយរយប៉ែត-សិបពីរ)ថ្ងៃ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ នៃខែណាមួយ ដោយគិតចាប់ពីថ្ងៃទទួលបានសិទ្ធិ
- មានសមាជិកភាពជាគណនេយ្យករជំនាញអាស៊ាន (ASEAN Certified Public Accountant-ASEAN CPA) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញលើសេវាគណនេយ្យ (ASEAN Mutual Recognition Arrangement on Accountancy Services) សម្រាប់បុគ្គលដាក់ពាក្យដែលមានសញ្ជាតិអាស៊ាន (ASEAN Nationality)
- បានចុះបញ្ជីជាគណនេយ្យករជំនាញបរទេស (Registered Foreign Public Accountant-RFPA) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញលើសេវាគណនេយ្យ (ASEAN Mutual Recognition Arrangement on Accountancy Services)



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៤៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

- ជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**)
- មានអាសយដ្ឋានស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាច្បាស់លាស់ និងពិតប្រាកដ
- មិនធ្លាប់ប្រព្រឹត្តល្មើសទៅនឹងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញនិងសវនករប្រតិស្រុតកម្ពុជា
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងរយៈពេល ១០ (ដប់) ឆ្នាំមុនពេលដាក់ពាក្យស្នើសុំ ដោយគិតចាប់ពីកាលបរិច្ឆេទប្រកាសសាលក្រម ឬសាលដីកាស្ថាពរ
- ជាបុគ្គលដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប(Fit and Proper)។

### ក.២. លក្ខខណ្ឌសម្រាប់ការស្នើសុំចុះបញ្ជីបន្ត (សិទ្ធិចុះហត្ថលេខា)

- ត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី ១៨២ (មួយរយប៉ែតសិបពីរ) ថ្ងៃ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ណាមួយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីបន្ត
- ជាសមាជិកសកម្មរបស់ **វ.គ.ស.ក.** និងមានអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ ឬ/និងសវនកម្ម មានសុពលភាពដែលចេញដោយ **ន.គ.ស.**
- មានសមាជិកភាពជាគណនេយ្យករជំនាញអាស៊ាន (ASEAN Certified Public Accountant) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញលើសេវាគណនេយ្យ (ASEAN Mutual Recognition Arrangement on Accountancy Services) សម្រាប់បុគ្គលដាក់ពាក្យដែលមានសញ្ជាតិអាស៊ាន (ASEAN Nationality)
- បានចុះបញ្ជីជាគណនេយ្យករជំនាញបរទេស (Registered Foreign Public Accountant) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញលើសេវាគណនេយ្យ (ASEAN Mutual Recognition Arrangement on Accountancy Services)
- មានអាសយដ្ឋានស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាច្បាស់លាស់និងពិតប្រាកដ
- មិនធ្លាប់ប្រព្រឹត្តល្មើសនឹងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតកម្ពុជា
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងរយៈពេល ១០ (ដប់) ឆ្នាំមុនពេលដាក់ពាក្យស្នើសុំ ដោយគិតចាប់ពីកាលបរិច្ឆេទប្រកាសសាលក្រម ឬសាលដីកាស្ថាពរ
- បានចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) តាមចំនួនម៉ោងដែលកំណត់ដោយ **វ.គ.ស.ក.**
- បានចូលរួមវគ្គបណ្តុះបណ្តាលនានាដែលរៀបចំដោយ **ន.គ.ស.**
- ជាបុគ្គលដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប(Fit and Proper)។

## ខ- ឯកសារភ្ជាប់

### ខ.១. រូបវន្តបុគ្គល

- ប្រវត្តិរូបសង្ខេប (CV)
- លិខិតឆ្លងដែនមានសុពលភាពយ៉ាងតិច៦ (ប្រាំមួយ) ខែ និងឯកសារបញ្ជាក់ថាបានរស់នៅព្រះរាជាណាចក្រកម្ពុជាស្របតាមលក្ខខណ្ឌតម្រូវ ដូចមានកំណត់ក្នុងចំណុច ក១ ឬ ក២
- វិញ្ញាបនបត្រគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) សម្រាប់បុគ្គលស្នើសុំមានសញ្ជាតិអាស៊ាន (ASEAN Nationality)
- វិញ្ញាបនបត្រចុះបញ្ជីគណនេយ្យករជំនាញបរទេស (RFPA) សម្រាប់បុគ្គលស្នើសុំមានសញ្ជាតិអាស៊ាន (ASEAN Nationality)

- លិខិត ឬវិញ្ញាបនបត្រសមាជិកសកម្មដែលចេញដោយ **វ.គ.ស.ក.**
- លិខិតថ្កោលទោសមានសុពលដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា
- ឯកសារបញ្ជាក់អំពីការចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) ចេញដោយ **វ.គ.ស.ក.**
- វិញ្ញាបនបត្រស្តីពីវគ្គបណ្តុះបណ្តាលនានា ដែលចេញដោយ **ន.គ.ស.**
- មានបណ្ណ ឬសៀវភៅការងារដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
- សេចក្តីចម្លងសញ្ញាបត្រខ្ពស់បំផុត និងសញ្ញាបត្រគណនេយ្យករជំនាញ ដោយមានការបញ្ជាក់ត្រឹមត្រូវ
- ឯកសារផ្សេងទៀត ដែលតម្រូវដោយអគ្គនាយកនៃ **ន.គ.ស.**។

### ខ.២. នីតិបុគ្គល

- ឯកសារបញ្ជាក់សារវតាក្រុមហ៊ុន និងរចនាសម្ព័ន្ធក្រុមហ៊ុន
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លិខិត ឬវិញ្ញាបនបត្រសមាជិកសកម្មដែលចេញដោយ **វ.គ.ស.ក.**
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
- បញ្ជីឈ្មោះនាយកសវនករ/ដៃគូសវនករ/ សវនករប្រតិស្រុត និងមន្ត្រីជាន់ខ្ពស់ និងប្រវត្តិរូបសង្ខេប
- នីតិវិធីសវនកម្ម ( សម្រាប់ក្រុមហ៊ុនសវនកម្ម )
- របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យជាធរមានសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ (ករណីការស្នើសុំបន្ត)
- អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈសវនកម្ម មានសុពលភាពដែលចេញដោយ **ន.គ.ស.**
- ឯកសារផ្សេងទៀត ដែលតម្រូវដោយអគ្គនាយកនៃ **ន.គ.ស.** ។

## គ- សិទ្ធិ និងកាតព្វកិច្ចរបស់គណនេយ្យករ និងសវនករប្រតិស្រុត ជាជនបរទេស

បន្ទាប់ពីទទួលបានការអនុញ្ញាតពី **ន.គ.ស.** គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស មានសិទ្ធិ និងកាតព្វកិច្ច ដូចខាងក្រោម÷

### គ.១. សិទ្ធិ

- មានសិទ្ធិធ្វើជានាយកសវនករ/ដៃគូសវនករ/ សវនករប្រតិស្រុត ដើម្បីសុំអាជ្ញាបណ្ណ/ ការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ ឬ/និង សវនកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់
- មានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និងរបាយកាណ៍សវនកម្ម។

### គ.២. កាតព្វកិច្ច

- គោរពបានយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតកម្ពុជា និងស្តង់ដាបច្ចេកទេសពាក់ព័ន្ធជាធរមាន
- ទិញធានារ៉ាប់រងវិជ្ជាជីវៈ ( សម្រាប់ក្រុមហ៊ុនសវនកម្ម )
- ទទួលខុសត្រូវពេញលេញលើរបាយការណ៍គណនេយ្យ ឬ/និងរបាយកាណ៍សវនកម្ម ដែលបានចុះហត្ថលេខាប្រកបដោយវិជ្ជាជីវៈ
- អនុវត្តតាមបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាតដែលមានជាធរមាន

- ប្រើប្រាស់បុគ្គលិកជនជាតិខ្មែរ ដោយគោរពតាមលក្ខខណ្ឌតម្រូវនានាស្របតាមច្បាប់ស្តីពីការងារ
- ធ្វើរបាយការណ៍អតិថិជនប្រចាំឆមាស និងប្រចាំឆ្នាំ ជូនអគ្គនាយកនៃ **ន.គ.ស.** យ៉ាងយូរក្នុងសប្តាហ៍ទី៣ នៃឆមាសទី២នៃឆ្នាំបច្ចុប្បន្ន និងសប្តាហ៍ទី៣នៃខែមករា ឆ្នាំបន្ទាប់ តាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.**
- សហការផ្តល់ព័ត៌មាននានាដែលតម្រូវដោយអគ្គនាយកនៃ **ន.គ.ស.**
- ជូនដំណឹងមក **ន.គ.ស.** ក្នុងរយៈពេល១៥ ថ្ងៃ មានជាអាទិ៍÷
    - ការផ្លាស់ប្តូរគណនេយ្យករជំនាញ/នាយកសវនករ/ដៃគូសវនករ ឬសវនករប្រតិស្រុត ក្នុងក្រុមហ៊ុន
    - ការព្យួរអាជ្ញាបណ្ណ ឬការឈប់ប្រកបវិជ្ជាជីវៈដោយខ្លួនឯង
    - ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគទុនិក
    - ការផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម ឬមធ្យោបាយទាក់ទង។
- បង់កម្រៃសេវាសាធារណៈស្របតាមបទប្បញ្ញត្តិជាធរមាន
- គោរព និងអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

**ឃ- ទោសទណ្ឌ**

រាល់ការមិនគោរពតាមលក្ខខណ្ឌតម្រូវ និងកាតព្វកិច្ចនានា តាមខ្លឹមសារនៃសារាចរណែនាំនេះ គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស និងនីតិបុគ្គលដែលមានគណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស នឹងត្រូវលុបសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និង របាយការណ៍សវនកម្ម ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ង- ការអនុវត្ត**

គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស ត្រូវមកដាក់ពាក្យស្នើសុំសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និង របាយការណ៍សវនកម្ម ដោយគោរពតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងសារាចរណែនាំនេះ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ តទៅ និងត្រូវយកចិត្តដាក់ក្នុងការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៣រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២

**អគ្គនាយក**

**ប៊ូ ចារិន**

**កន្លែងទទួល÷**

- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ស.ហ.វ. និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.

  " ដើម្បីគោរពជូនជ្រាប "
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

  " ដើម្បី ជូនជ្រាបនិងសហការអនុវត្ត "
- ឯកសារ-កាលប្បវត្តិ